**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...០៧...សរ.....

# សារាចរ

## ស្តីពី

## ការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិលនិងមន្ត្រីសាធារណៈផ្សេងទៀត

ដើម្បីធានាការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិលនិងមន្ត្រីសាធារណៈផ្សេងទៀត ដែលស្ថិតក្នុងតារាងបៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈបានឆាប់រហ័ស ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ នៅរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងអង្គភាពរដ្ឋបាលថ្នាក់ជាតិ និងអង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

១. ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងគ្រួសារមន្ត្រីរាជការក្នុងតារាងបៀវត្សនៃខែនីមួយៗ

- គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តល់ឯកសារស្នើសុំផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងគ្រួសារមន្ត្រីរាជការ មកក្រសួងមុខងារសាធារណៈឱ្យបានមុនដំណាច់សប្តាហ៍ទី២ នៃខែនីមួយៗដើម្បីរៀបចំបើកផ្តល់បៀវត្សក្នុងខែបន្ទាប់
- ក្រសួងមុខងារសាធារណៈ ត្រូវធ្វើការណែនាំលម្អិតអំពីបែបបទ ឯកសារតម្រូវនិងទម្រង់ឯកសារពាក់ព័ន្ធ និងការស្នើសុំផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការក្នុងតារាងទូទាត់បៀវត្សនៃខែនីមួយៗ ដល់គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

២. ការផ្តល់តារាងទូទាត់បៀវត្សដល់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- ក្រសួងមុខងារសាធារណៈ ត្រូវផ្តល់តារាងទូទាត់បៀវត្សនៃខែនីមួយៗដោយភ្ជាប់ជាមួយនូវអាណត្តិបើកប្រាក់ទៅឱ្យគ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ យ៉ាងយូរត្រឹមសប្តាហ៍ទី៤ នៃខែនីមួយៗ ដើម្បីរៀបចំបើកផ្តល់បៀវត្សខែបន្ទាប់។

៣. ការរៀបចំអាណត្តិបើកប្រាក់បៀវត្ស

- ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំបើកផ្តល់បៀវត្សនៅរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ផ្អែកលើតារាងទូទាត់បៀវត្សនៃខែនីមួយៗនិងអាណត្តិបើកប្រាក់បៀវត្សដែលផ្តល់ដោយក្រសួងមុខងារសាធារណៈ
- អាណត្តិបើកប្រាក់បៀវត្សត្រូវរៀបចំសម្រាប់តែចំណាយលើបៀវត្សតែប៉ុណ្ណោះ។

៤. ការពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្ស

៤.១ ថ្នាក់កណ្តាល

- រដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័ន ក្នុងនាមជាអាណាប័កដើមខ្សែ និងប្រធានអង្គភាពរដ្ឋបាលថ្នាក់ជាតិ ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ ពិនិត្យនិងចុះហត្ថលេខាដោយផ្ទាល់លើអាណត្តិបើកប្រាក់បៀវត្ស ឬ
- រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ឬ ប្រធានអង្គភាពរដ្ឋបាលថ្នាក់ជាតិ អាចធ្វើប្រតិភូកម្មដល់អាជ្ញាធរក្រោមបង្គាប់ ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្សក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិដូចខាងក្រោម៖
    - អគ្គនាយក ឬ អគ្គលេខាធិការទទួលបន្ទុកនាយកដ្ឋានហិរញ្ញវត្ថុ ឬ អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ន ឬ
    - ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ឬ ប្រធានអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ន
    - អនុប្រធានអង្គភាពរដ្ឋបាលថ្នាក់ជាតិ ឬ ប្រធាននាយកដ្ឋាន/ប្រធានការិយាល័យគណនេយ្យហិរញ្ញវត្ថុនៃអង្គភាពរដ្ឋបាលថ្នាក់ជាតិ។
- អាណត្តិបើកប្រាក់បៀវត្ស ដែលត្រូវបានចុះហត្ថលេខាដោយអាណាប័ក និងទទួលបានទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង ស្ថាប័ន ត្រូវបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ) យ៉ាងយូរត្រឹមថ្ងៃទី៤ ក្នុងសប្តាហ៍ទី១នៃខែដែលត្រូវបើកផ្តល់បៀវត្ស។ ក្នុងករណីពុំទាន់មានមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំនៅក្រសួង ស្ថាប័ន អាណត្តិបើកប្រាក់បៀវត្ស ដែលត្រូវបានចុះហត្ថលេខាដោយអាណាប័ករួចហើយ ត្រូវបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) យ៉ាងយូរត្រឹមថ្ងៃទី១ ក្នុងសប្តាហ៍ទី១ នៃខែដែលត្រូវបើកផ្តល់បៀវត្ស ដើម្បីទទួលបានទិដ្ឋាការ រួចត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ យ៉ាងយូរត្រឹមថ្ងៃទី៤ ក្នុងសប្តាហ៍ទី១ នៃខែដែលត្រូវបើកផ្តល់បៀវត្ស។

៤.២ ថ្នាក់មូលដ្ឋាន

- អភិបាលនៃគណៈអភិបាល និងមេឃុំ ចៅសង្កាត់ ក្នុងនាមជាអាណាប័ក ពិនិត្យនិងចុះហត្ថលេខាដោយផ្ទាល់ ឬ ប្រគល់សិទ្ធិដល់អភិបាលរង និង ជំទប់ ឬ ចៅសង្កាត់រង ផ្អែកលើករណីពាក់ព័ន្ធនីមួយៗ ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការបម្រើការងារនៅរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលខណ្ឌ រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់
- ប្រធានមន្ទីរ ឬ អង្គភាពពាក់ព័ន្ធក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិពីរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័ន ឬ ប្រធានអង្គភាពពាក់ព័ន្ធ ពិនិត្យនិងចុះហត្ថលេខាដោយផ្ទាល់ ឬ ប្រគល់សិទ្ធិដល់អនុប្រធានដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការបម្រើការងារក្នុងមន្ទីរ ឬ អង្គភាពពាក់ព័ន្ធ
- អាណត្តិបើកប្រាក់បៀវត្ស ត្រូវបានបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយូរត្រឹមថ្ងៃទី១ ក្នុងសប្តាហ៍ទី១ នៃខែដែលត្រូវបើកផ្តល់បៀវត្ស រួចបញ្ជូនទៅរតនាគាររាជធានី ខេត្តយ៉ាងយូរត្រឹមថ្ងៃទី៤ ក្នុងសប្តាហ៍ទី១ នៃខែដែលត្រូវបើកផ្តល់បៀវត្ស។

៥. ការបើកផ្តល់បៀវត្សដល់មន្ត្រីរាជការស៊ីវិលនិងមន្ត្រីសាធារណៈផ្សេងទៀត៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ៖ រតនាគារថ្នាក់កណ្តាលនិងរតនាគាររាជធានី ខេត្ត) ត្រូវចាត់ចែងការត្រួតពិនិត្យនិងរៀបចំបើកផ្តល់បៀវត្សដល់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានទាន់ពេលវេលានៅរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ក្នុងនោះ ៖ លើកទី១ ឱ្យបានទាន់ក្នុងសប្តាហ៍ទី២ និងលើកទី២ ឱ្យបានទាន់ក្នុងសប្តាហ៍ទី៤ បន្ទាប់ពីទទួលបានអាណត្តិបើកប្រាក់បៀវត្សពីក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិតាមកាលកំណត់ខាងលើ
- ក្នុងករណីក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មិនបានបញ្ជូនអាណត្តិបើកប្រាក់បៀវត្សដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមកាលកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ៖ រតនាគារថ្នាក់កណ្តាលនិងរតនាគាររាជធានី ខេត្ត) ត្រូវចាត់ចែងបើកផ្តល់បៀវត្សដល់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដោយធ្វើការបុរេប្រទានសាច់ប្រាក់ផ្អែកលើតារាងទូទាត់បៀវត្សដែលផ្តល់ដោយក្រសួងមុខងារសាធារណៈ ឱ្យបានទាន់ពេលវេលាកំណត់ ដោយចាត់ទុកថាក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិបានឯកភាពជាស្វ័យប្រវត្តិលើការទូទាត់បើកផ្តល់បៀវត្សនោះ ប៉ុន្តែក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តល់លិខិតយុត្តិការចំណាយ និងអាណត្តិនិយតកម្មដែលចុះហត្ថលេខារួច ដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្អែកលើករណីពាក់ព័ន្ធនីមួយៗ ហើយបញ្ជូនបន្តទៅអគ្គនាយកដ្ឋានរតនាគារជាតិ (រតនាគារថ្នាក់កណ្តាលនិងរតនាគាររាជធានី ខេត្ត) ដើម្បីធ្វើការទូទាត់ជម្រះបញ្ជីបុរេប្រទាននោះតាមក្រោយឱ្យស្របតាមនីតិវិធីហិរញ្ញវត្ថុ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំកំណត់បែបបទនិងនីតិវិធីហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងរៀបចំតារាងពេលវេលានៃការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ដោយកំណត់ថ្ងៃជាក់លាក់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមលំដាប់លំដោយក្នុងសប្តាហ៍ទី២ និងសប្តាហ៍ទី៤ នៃខែនីមួយៗ។

៦. គណនេយ្យភាពនិងការទទួលខុសត្រូវ

- អាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្ស ដូចដែលបានចង្អុលបង្ហាញខាងលើ ត្រូវចាត់ចែងបំពេញភារកិច្ចដោយផ្ទាល់ ឬ ធ្វើប្រតិភូកម្មដល់អាជ្ញាធរស្ថិតក្រោមបង្គាប់ដើម្បីបំពេញការងារឱ្យទាន់ពេលវេលាកំណត់
- អាជ្ញាធរមានសមត្ថកិច្ចដែលត្រូវអនុវត្តភារកិច្ចតាមខ្លឹមសារនៃសារាចរនេះ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើកម្រិតឋានានុក្រម និងមន្ត្រីរាជការដែលត្រូវទទួលបៀវត្សក្នុងខែនីមួយៗ ព្រមទាំងត្រូវមានការទទួលខុសត្រូវផ្សេងទៀតជាយថាហេតុផ្អែកលើបទប្បញ្ញត្តិច្បាប់ជាធរមាន។

ទទួលបានសារាចរនេះគ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវ។

ថ្ងៃ ចន្ទ ៥ កើត ខែ មិគសិរ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ១១ ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ